**មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF III)**

# សេចក្តីប្រកាសព័ត៌មានរួម

## ប្រទេសកម្ពុជានឹងវាយតម្លៃការសិក្សាសិស្សានុសិស្ស ដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្រោយជំងឺរាតត្បាតកូវីដ

**រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២២៖** នៅក្នុងខែមិថុនាឆ្នាំនេះ ក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានចូលរួមនៅក្នុងកម្មវិធីវាយតម្លៃសិស្សអន្តរជាតិ (PISA) ដែលជាជំហានដ៏សំខាន់ឆ្ពោះទៅរកការស្វែងយល់អំពីលទ្ធផលសិក្សារបស់សិស្សានុសិស្ស ដោយពិនិត្យមើលយ៉ាងយកចិត្តទុកដាក់លើចំណេះដឹងដែលអ្នកសិក្សាបានចេះដឹង ដោយវាស់វែងទៅលើការត្រៀមខ្លួនរបស់យុវជនកម្ពុជាសម្រាប់ពេលអនាគត និងដោយតម្រង់ទិសកិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញក្រោយជំងឺរាតត្បាតកូវីដ-១៩ ។ លទ្ធផលទាំងនេះត្រូវបានរំពឹងទុកថានឹងទទួលបាននៅដើមឆ្នាំ២០២៣ ។

ដោយបានដាក់ឱ្យដំណើរការដោយអង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ (OECD) កម្មវិធីវាយតម្លៃ PISA ធ្វើតេស្តសមត្ថភាពសិស្សានុសិស្សដែលមានអាយុ១៥ឆ្នាំ ទៅលើការប្រើប្រាស់នូវជំនាញ និងចំណេះដឹងរបស់ពួកគេលើអំណាន គណិតវិទ្យា និងវិទ្យាសាស្ត្រ សម្រាប់យកមកប្រើប្រាស់ដើម្បីជំនះរាល់បញ្ហាប្រឈមនានាក្នុងជីវិតពិតរបស់ខ្លួន។ លទ្ធផលទាំងនេះនឹងត្រូវផ្សព្វផ្សាយដោយអង្គការ OECD សម្រាប់ប្រទេសទាំងអស់ដែលបានចូលរួមនៅក្នុងកម្មវិធីវាយតម្លៃ PISA នេះ។ ចាប់តាំងពីការចាប់ផ្តើមនៅក្នុងឆ្នាំ២០០០មក កម្មវិធី PISA បានក្លាយជាស្តង់ដារសាកលនៅក្នុងការវាយតម្លៃលើសមិទ្ធផល និងវឌ្ឍនភាពរបស់សាលា ហើយបាននឹងកំពុងដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផ្លាស់ប្តូរគោលនយោបាយ ពីការផ្តោតការយកចិត្តទុកដាក់លើធាតុចូលអប់រំ ទៅលើការយកចិត្តទុកដាក់ចំពោះលទ្ធផលសិក្សាវិញ នៅក្នុងសម្រេចចិត្តរបស់រដ្ឋាភិបាល និងការរៀបចំគោលនយោបាយ។

នេះគឺជាលើកដំបូងហើយ ដែលប្រទេសកម្ពុជាបានចូលរួមនៅក្នុងកម្មវិធីនេះ។ គំនិតផ្តួចផ្តើមនេះត្រូវបានដឹកនាំ និងផ្តល់ថវិកាមួយផ្នែកដោយក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងវិភាគទានហិរញ្ញវត្ថុបន្ថែមពីមូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ (CDPF) គាំទ្រដោយប្រទេសមួយចំនួន រួមមានសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត (SIDA) ភាពជាដៃគូជាសកលសម្រាប់ការអប់រំ (GPE) និងមូលនិធិសហប្រជាជាតិដើម្បីកុមារ (UNICEF) ផងដែរ ។

EUROPEAN UNION　ស៊ុយអែត Sverige　GPE Transforming Education　USAID　unicef for every child

## មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF III)

ទិន្នន័យរបស់កម្មវិធី PISA នឹងគាំទ្រក្រសួងអប់រំ យុវជន និងកីឡា ក្នុងការកំណត់គោលដៅអន្តរាគមន៍ និងកំណត់អំពីវិធីសាស្ត្រល្អបំផុតសម្រាប់ផ្តល់ការអប់រំប្រកបដោយគុណភាពដល់សិស្សានុសិស្សទាំងអស់ ក៏ដូចជាជួយដល់ពួកគេក្នុងការស្តារឡើងវិញពីការបាត់បង់ការសិក្សាបង្កដោយជំងឺឆ្លងរាតត្បាតនេះ ។ ការវិភាគនាពេលថ្មីៗនេះលើការវាយតម្លៃលទ្ធផលសិក្សាថ្នាក់ជាតិសិស្សថ្នាក់ទី៦ ដែលក៏ត្រូវបានគាំទ្រដោយមូលនិធិ CDPF ដែរនោះ បានរកឃើញយ៉ាងច្បាស់នូវការបាត់បង់ការសិក្សាយ៉ាងធ្ងន់ធ្ងររបស់សិស្សានុសិស្ស ដោយសារតែការបិទសាលារៀនបណ្តាលមកពីជំងឺកូវីដ-១៩ ។ ការស្វែងយល់អំពីកម្រិតសិក្សាបច្ចុប្បន្នរបស់កុមារ ពិតជាអាចជួយដល់អ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ អាចវាស់វែងបាននូវវឌ្ឍនភាពទៅតាមកាលវេលា ប៉ុន្តែចំណុចសំខាន់ជាងនេះទៀតនោះ គឺវាបានផ្តល់នូវទិន្នន័យផ្អែកលើភស្តុតាង សម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្ត ដើម្បីគាំទ្រកាន់តែប្រសើរដល់សាលារៀន គ្រូបង្រៀន និងសិស្សានុសិស្ស នៅក្នុងការផ្តល់នូវទិសដៅ និងបង្ហាញនូវមាគ៌ាស្តារការសិក្សាឡើងវិញ ហើយជាលទ្ធផលគឺសំដៅទៅរកការបង្រៀន និងការរៀនសូត្រនាពេលអនាគតដ៏មានគុណភាពប្រសើរជាងមុន។

ដៃគូរបស់មូលនិធិ CDPF កំពុងគាំទ្រក្រសួងអប់រំ យុវជន និងកីឡា លើគ្រប់ទិដ្ឋភាពនៃការស្តារការសិក្សាឡើងវិញ ដោយចាប់ផ្តើមពីការគាំទ្រផ្ទាល់ដល់កុមារ បង្កលទ្ធភាពឱ្យពួកគេអាចចូលរៀនឡើងវិញ និងបន្តរៀននៅក្នុងសាលា។ កម្មវិធីមូលដ្ឋានគ្រឹះសិក្សា "**អំណានថ្នាក់ដំបូង**" និង "**គណិតវិទ្យាថ្នាក់ដំបូង**" បាននឹងកំពុងអនុវត្តនៅក្នុងខេត្តចំនួន១២ ដែលជាជំហានដ៏សំខាន់មួយឆ្ពោះទៅរកការជួយកុមារកម្ពុជាបង្កើននូវជំនាញអំណាន និងជំនាញគិតលេខរបស់ពួកគេ ហើយតាមរយៈការផ្តោតលើជំនាញកម្រិតដំបូងទាំងនេះ នោះពួកគេនឹងអាចសិក្សាបន្តទៅមុខទៀតបាន ។

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍ថា "កម្ពុជាមានសេចក្តីសោមនស្សរីករាយ ដែលបានចូលរួមក្នុងក្របខ័ណ្ឌវាយតម្លៃជាសាកលនេះ។ យើងរំពឹងទុកនូវការយល់ដឹងកាន់តែប្រសើរអំពីកម្រិតការសិក្សារបស់សិស្សានុសិស្ស ព្រោះវាមានសារៈសំខាន់ណាស់ ដើម្បីធានាថាអន្តរាគមន៍នានារបស់យើងនឹងធ្វើឡើងចំគោលដៅយ៉ាងត្រឹមត្រូវ។ ក្រសួងអប់រំ យុវជន និងកីឡា កំពុងវិនិយោគជាច្រើនលើការសិក្សារបស់សិស្សនៅថ្នាក់ដំបូង លើកកម្ពស់ជំនាញគ្រូបង្រៀន និងការអប់រំតាមឌីជីថល ដែលការវិនិយោគទាំងអស់នេះនឹងជួយយើងឱ្យជំនះបញ្ហាប្រឈមនានាចំពោះការសិក្សាដែលបង្កឡើងដោយការបិទសាលារៀនដោយសារជំងឺកូវីដ-១៩ ។"

លោកជំទាវ ខាម៉ិន ម៉ូរ៉េណូ ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជាបានមានប្រសាសន៍ថា "ទិន្នន័យ និងការស្រាវជ្រាវប្រកបដោយគុណភាព គឺមានសារសំខាន់ណាស់សម្រាប់ការរៀបចំគោលនយោបាយល្អ ។ យើងពិត

ជាអាចដោះស្រាយបញ្ហាបាន នៅពេលយើងអាចកំណត់ដឹងពីបញ្ហាទាំងនោះបានច្បាស់លាស់។ ទិន្នន័យជាពិសេសការស្រាវជ្រាវដែលអាចប្រៀបធៀបគ្នាបានជាមួយប្រទេសផ្សេងៗ អាចជួយយើងនៅក្នុងការស្វែងយល់អំពីបញ្ហានានាកាន់តែប្រសើរឡើង។ ដើម្បីធានាថាថវិកាសាធារណៈត្រូវបានចំណាយចំគោលដៅកាន់តែប្រសើរ យើងត្រូវវាយតម្លៃលើអន្តរាគមន៍ និងគោលនយោបាយ ថាពិតជាសម្រេចបាននូវលទ្ធផលដែលយើងបានរំពឹងទុកដែរឬយ៉ាងណា ។ ជាថ្មីម្តងទៀត ទិន្នន័យ និងភស្តុតាងទាំងនេះធ្វើឱ្យយើងមានភាពខ្លាំង ហើយវាជួយយើងនៅក្នុងការសម្រេចចិត្តថាតើដំណោះស្រាយដែលបានស្នើឡើងនោះ អាចប្រព្រឹត្តទៅតាមទិសដៅត្រឹមត្រូវឬទេ។ ដូច្នេះមានន័យថាយើងបានចំណាយត្រឹមត្រូវ សម្រាប់លទ្ធផលដែលយើងចង់បាន។ សហភាពអឺរ៉ុប (EU) មានមោទនភាពនៅក្នុងការធ្វើជាដៃគូជាមួយកម្ពុជានៅក្នុងការរៀបចំគោលនយោបាយផ្អែកលើភស្តុតាងនេះ”។

លោកស្រី រីបេខា ប្លេក នាយិកាបេសកកម្មស្តីទីរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ប្រចាំកម្ពុជាបានមានប្រសាសន៍ថា “ខ្ញុំមានសេចក្តីសប្បាយរីករាយនៅក្នុងការតាមដានវឌ្ឍនភាពយ៉ាងទៀងទាត់នៃកំណែទម្រង់ប្រព័ន្ធអប់រំកម្ពុជាចាប់តាំងពីឆ្នាំ២០១៣មក។ កម្មវិធីវាយតម្លៃ PISA ពិតជាបំពេញបន្ថែមឱ្យការវាយតម្លៃអំណានថ្នាក់ដំបូងយ៉ាងប្រសើរ ដែល USAID បាននឹងកំពុងអនុវត្តការវាយតម្លៃនេះជាមួយនឹងអ្នកជំនាញកម្ពុជា ដើម្បីពិនិត្យមើលការសិក្សារបស់សិស្សានុសិស្សនៅថ្នាក់បឋមសិក្សា ។ យើងខ្ញុំមានមោទនភាពដែលបានធ្វើជាដៃគូ នៅក្នុងគំនិតផ្តួចផ្តើមដ៏សំខាន់នេះ នៅក្នុងការប្រមូល និងប្រើប្រាស់ទិន្នន័យដោយតម្លាភាព នៅក្នុងវិស័យអប់រំ ។”

លោកស្រី ហ្វ៊ូហ្គ ហ្វយូហ្សិថ នាយិកាយូនីសេហ្វប្រចាំកម្ពុជាបានមានប្រសាសន៍ថា “យើងបានឃើញផល ប៉ះពាល់ធ្ងន់ធ្ងរបង្កដោយជំងឺកូវីដ-១៩ ដែលធ្វើឱ្យមានវិសមភាពកាន់តែខ្លាំងឡើងនៅទូទាំងសកលលោក។ ការវិនិយោគលើការអប់រំ ជាពិសេសការចាត់វិធានការសមស្រប និងបន្ទាន់ ដើម្បីឆ្លើយតបនឹងការបាត់បង់ ការសិក្សាធ្ងន់ធ្ងររបស់កុមារ ដោយសារការរិតត្បឹតនានាបណ្តាលមកពីជំងឺកូវីដ គឺមានសារៈសំខាន់ណាស់ ដើម្បីទប់ស្កាត់ និងស្តារស្ថានភាពឱ្យប្រសើរឡើងវិញនេះ។ ការទទួលបានដោយសមធម៌នូវការអប់រំប្រកបដោយ គុណភាពមានតួនាទីដ៏សំខាន់នៅក្នុងការពង្រឹងធនធានមនុស្សនៅក្នុងប្រទេសកម្ពុជា និងធានាថាកុមារគ្រប់រូប អាចទទួលបានចំណេះដឹង ជំនាញ និងសមត្ថភាពមូលដ្ឋាន ដែលពួកគេត្រូវការ ដើម្បីត្រាយផ្លូវសម្រាប់អនាគត របស់ខ្លួននាអនាគតខាងមុខ ។”

# មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាពវិស័យអប់រំ (CDPF III)

សារតា៖

## មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ(CDPF)៖

មូលនិធិភាពជាដៃគូសម្រាប់អភិវឌ្ឍន៍សមត្ថភាពវិស័យអប់រំ (CDPF) គឺជាភាពជាដៃគូរវាងក្រសួងអប់រំ យុវជន និងកីឡានៅកម្ពុជា (MoEYS) និងសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារស៊ុយអែតសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (SIDA) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (USAID) ភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) និងយូនីសេហ្វ។ តាមរយៈយន្តការផ្តល់មូលនិធិរួម CDPF ផ្តល់ការគាំទ្រក្នុងការអនុវត្តអាទិភាពអភិវឌ្ឍន៍សមត្ថភាពនៅក្នុងវិស័យអប់រំ។ CDPF បានឈានចូលដល់ដំណាក់កាលទីបីរបស់ខ្លួននៅឆ្នាំ២០១៨ ដែលនឹងបន្តរហូតដល់ខែមិថុនា ឆ្នាំ២០២៣ ដោយគាំទ្រដល់គំនិតផ្តួចផ្តើមកសាងសមត្ថភាពនៅក្នុងវិស័យអប់រំ ជាមួយនឹងមូលនិធិចំនួនប្រមាណ៣៧លានដុល្លារអាមេរិក។ ដំណាក់កាលថ្មីនេះពង្រឹងបន្ថែមលើភាពជោគជ័យនៃដំណាក់កាលចំនួនពីរដំបូង ដែលត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០១១ ដោយមានមូលនិធិសរុបចំនួន ២៤ លានដុល្លារអាមេរិក។

## សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


- ឯកឧត្តមបណ្ឌិត រស់ សុវាចា អ្នកនាំពាក្យក្រសួងអប់រំ យុវជន និងកីឡា
  ទូរសព្ទ៖ +៨៥៥ ៧៨ ៧៥៥ ៥៥៦ ឬសារអេឡិកត្រូនិក៖ soveacha2002@yahoo.com
- អ្នកស្រី រូឌីណា វ៉ូវ៉ូដា ប្រធានផ្នែកទំនាក់ទំនង យូនីសេហ្វ
  ទូរសព្ទ៖ (+៨៥៥) ៩២ ៥៥៥ ២៩៤ ឬ សារអេឡិកត្រូនិក៖ rvojvoda@unicef.org
- លោក មាស ប៊ុនលី មន្ត្រីជំនាញផ្នែកទំនាក់ទំនង យូនីសេហ្វ
  ទូរសព្ទ៖ +៨៥៥ ១២ ៧៣៣ ៩០៩ ឬសារអេឡិកត្រូនិក៖ bmeas@unicef.org